ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តកំពង់ធំ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣១១ ចុះថ្ងៃទី ០៦
ខែ កក្កដា ឆ្នាំ ២០០៥
សាលក្រម
លេខ ៧៥ "ក" ចុះថ្ងៃទី ២២
ខែ វិច្ឆិកា ឆ្នាំ ២០០៥

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**
លោក [redacted]
**តំណាងអយ្យការ**
លោក [redacted]
**ក្រឡាបញ្ជីសវនាការ**
លោក [redacted]

សាលក្រមនេះចូលស្ថានភាពជាស្ថាពរចាប់តាំងពីថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦
តទៅដោយគ្មានបណ្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។
កំពង់ធំ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៦
ក្រឡាបញ្ជីតុលាការខេត្ត
[redacted]

**ដើម្បីជំនុំជំរះ :**

លើជនជាប់ចោទ ជនមិនស្គាល់ឈ្មោះ "អញ្ញាតជន" គ្មានសាវតារជាតិ ពីបទ : **ប្រើប្រាស់រណាយន្តប្រមូលផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ** ប្រព្រឹត្តនៅចំណុចក្របីលង់ ឃុំទីវង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៩ កថាខណ្ឌទី១ ចំណុចទី១ នៃច្បាប់ស្តីពីព្រៃឈើ ។

-បានឃើញដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជំរះផ្ទាល់លេខ ៥៩ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ របស់អយ្យការអមតុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៩៦០ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ របស់តុលាការខេត្តកំពង់ធំ ។

## ការប្រព្រឹត្តិរបស់ជនជាប់ចោទ

កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ សមត្ថកិច្ចរដ្ឋបាលព្រៃឈើសង្កាត់ទីវង បានចុះប្រតិបត្តិការនៅចំណុចក្របីលង់ ឃុំទីវង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ប្រទះឃើញជនល្មើសកំពុងប្រើប្រាស់រណាយន្តអារច្រៀកឈើ ដោយគ្មានលិខិតអនុញ្ញាត តែពេលសមត្ថកិច្ចសំរុកចូលទៅកន្លែងកើតហេតុជនល្មើសបានគេចខ្លួនបាត់ សមត្ថកិច្ចក៏បានយកឈើវត្ថុតាងទាំងនោះមករក្សាទុក នៅសង្កាត់រដ្ឋបាលព្រៃឈើទីវង ជាបណ្តោះ



Scanned with CamScanner

អាសន្ន ។

-បានឃើញកំណត់ហេតុបទល្មើសជាក់ស្តែង ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ របស់សមត្ថកិច្ចរដ្ឋបាលព្រៃឈើទីរឹង បញ្ជាក់ថា :

១-កន្លែងកើតហេតុនៅចំណុចក្រឹបលង់ ឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ

២-ប្រភេទបទល្មើសប្រើប្រាស់រណារយន្តប្រមូលផលអនុផលព្រៃឈើ គ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ

៣-វត្ថុតាងមានរណារយន្ត ០១គ្រឿង ម៉ាកស្ទីល ០៧០ លេខ : S១៥៥៩៥៦៣៧៩

៤-ប្រព្រឹត្តដោយជនល្មើសមិនស្គាល់មុខ

៥-នៅពេលត្រួតពិនិត្យជនល្មើសបានគេចខ្លួនបាត់

៦-បន្ទាប់ពីបានពិនិត្យជាក់ស្តែងឃើញថា ប្រើប្រាស់រណារយន្តអនុផលព្រៃឈើខាងលើប្រាសចាកពីច្បាប់ស្តីពីព្រៃឈើ ហើយបានបញ្ជូនកំណត់ហេតុអំពើល្មើសជាក់ស្តែងនេះ ទៅសមត្ថកិច្ចថ្នាក់លើដើម្បីសំរេច ។

-បានឃើញកំណត់ហេតុនៃបទល្មើស ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៥ របស់រដ្ឋបាលព្រៃឈើទីរឹង បានបញ្ជាក់ថា កាលពីថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៥ វេលាម៉ោង ៧.៣០នាទី យើងបានទទួលរបាយការណ៍លេខ ៣១ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ របស់សង្កាត់រដ្ឋបាលព្រៃឈើទីរឹង ស្តីពីការចាប់ឃាត់រណារយន្ត ០១គ្រឿង ម៉ាកស្ទីល ០៧០ លេខ S១៥៥៩៥៦៣៧៩ ដែលជនល្មើសចូលមកធ្វើអាជីវកម្ម គ្មាន លិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ នៅចំណុចក្រឹបលង់ ឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ហើយរត់គេចខ្លួនបាត់ ។ វត្ថុតាងល្មើសត្រូវបានយកមកប្រគល់ឱ្យលោក ឃ្ម [redacted] ទទួលរក្សាទុកជាបណ្តោះអាសន្ន នៅសង្កាត់រដ្ឋបាល ព្រៃឈើទីរឹង ។

-បានឃើញលិខិតទទួលថែរក្សា ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ បញ្ជាក់ថា ឈ្មោះ ឃ្ម [redacted] បានទទួលថែរក្សាវត្ថុតាងមាន រណារយន្តម៉ាកស្ទីល ០៧០ លេខ S១៥៥៩៥៦៣៧៩ មួយគ្រឿង ។

## <u>នាពេលសវនាការ</u>

លោក ឃិន [redacted] នាយរងផ្នែករដ្ឋបាលព្រៃឈើទីរឹង ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយថា កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ សមត្ថកិច្ចរដ្ឋបាលព្រៃឈើសង្កាត់ទីរឹង ចុះប្រតិបត្តិការនៅចំណុចក្រឹបលង់ ឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ បានប្រទះឃើញជនល្មើសកំពុងប្រើប្រាស់រណារយន្តអារច្រៀកឈើ ដោយគ្មានលិខិតអនុញ្ញាត តែពេលសមត្ថកិច្ចសំរុកចូលទៅកន្លែងកើតហេតុ ជនល្មើសបានគេចខ្លួនបាត់ ដោយបានបន្សល់ទុកនៅកន្លែងកើតហេតុមានរណារយន្តវត្ថុតាង ០១គ្រឿងម៉ាកស្ទីល ០៧០ លេខ S១៥៥៩៥៦៣៧៩ សមត្ថកិច្ចក៏បានយករណារយន្តវត្ថុតាងនេះមកប្រគល់ឱ្យលោក ឃ្ម [redacted] ទទួលរក្សាទុកនៅសង្កាត់រដ្ឋបាលព្រៃឈើទីរឹង ជាបណ្តោះអាសន្នរង់ចាំការសំរេចពីតុលាការ ។ សំណូមពរតុលាការរឹបអូសវត្ថុតាងជាប្រយោជន៍សម្បត្តិរដ្ឋ ។

តំណាងអយ្យការធ្វើសន្និដ្ឋានថា មានពិរុទ្ធភាពធ្ងន់ធ្ងរលើជនជាប់ចោទមិនស្គាល់ឈ្មោះ ពីបទ : ប្រើប្រាស់រណារយន្តប្រមូលផលអនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅចំណុចក្រឹបលង់ ឃុំទីរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ ។ ដូច្នេះអយ្យការសំរេចតំកល់ដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងជំនុំជំរះផ្ទាល់លេខ ៥៥ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ របស់អយ្យការទុកជាបានការ



Scanned with CamScanner

ពេញទាំងមូល សុំតុលាការសំរេចរឹបអូសវត្ថុតាងជាប្រយោជន៍សម្បត្តិរដ្ឋតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ធំ

## យល់ឃើញថា

-កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ សមត្ថកិច្ចរដ្ឋបាលព្រៃឈើសង្កាត់ទីរីង បានចុះប្រតិបត្តិការនៅចំណុចក្របីលង់ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ប្រទះឃើញជនល្មើសកំពុងប្រើប្រាស់រណាយន្តអារច្រៀកឈើ ដោយគ្មានលិខិតអនុញ្ញាត តែពេលសមត្ថកិច្ចសំរុកចូលទៅកន្លែងកើតហេតុ ជនល្មើសបានគេចខ្លួនបាត់ សមត្ថកិច្ចក៏បានយកឈើវត្ថុតាងនោះ មករក្សាទុកនៅសង្កាត់រដ្ឋបាលព្រៃឈើទីរីង ជាបណ្តោះអាសន្ន ។

-ជនជាប់ចោទជាជនមិនស្គាល់មុខ "អញ្ញាតជន" គ្មានសាវតារជាតិ ។ ដូច្នេះតុលាការត្រូវសំរេចបង្គង់បណ្តឹងអាជ្ញាលើជនជាប់ចោទជាអញ្ញាតជននេះ ។

-សមត្ថកិច្ចរដ្ឋបាលព្រៃឈើបានប្រកាសស្រាវជ្រាវរកជនល្មើស ឱ្យបង្ហាញលិខិតអនុញ្ញាតក្នុងរយៈពេល ៣០ថ្ងៃ តាមកំណត់ច្បាប់ហើយ តែគ្មានជនណាម្នាក់ចេញមុខបង្ហាញលិខិតអនុញ្ញាតទេ ឃើញថា រណាយន្ត ០១គ្រឿងម៉ាកស្ទីល ០៧០ លេខ ៥១៥៥៩៥៦៣៧៩ ដែលសមត្ថកិច្ចប្រមូលបានពីកន្លែងកើតហេតុ គឺពិតជាវត្ថុតាងនៃអំពើល្មើសច្បាប់ អារច្រៀកឈើ ដោយប្រើប្រាស់រណាយន្តនេះ គ្មានលិខិតអនុញ្ញាតប្រាកដមែន ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ

## វិនិច្ឆ័យសេចក្តី

១-បង្គង់បណ្តឹងអាជ្ញា លើជនជាប់ចោទមិនស្គាល់មុខ "អញ្ញាតជន" គ្មានសវតាជាតិ ពីបទ : **ប្រើប្រាស់រណាយន្តប្រមូលផលអនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត** ប្រព្រឹត្តនៅចំណុចក្របីលង់ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥ ។

២-សំរេចរឹបអូសវត្ថុតាងមានរណាយន្ត ០១គ្រឿងម៉ាកស្ទីល ០៧០ លេខ ៥១៥៥៩៥៦៣៧៩ ជាប្រយោជន៍សម្បត្តិរដ្ឋ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខ លោក **ឃិន** [redacted] តំណាងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០២ខែ តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

[redacted]



Scanned with CamScanner